លេខបញ្ជីពាណិជ្ជកម្ម៖
Co. ០៨៣៩ Et/២០១២

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

# ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន
# សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧

ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដែលភ្ជាប់មកជាមួយ គឺជាការប្រែសំរួលជាភាសាខ្មែរ ពីរបាយការណ៍ជាភាសាអង់គ្លេស។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ ឯកសារអង់គ្លេស ត្រូវបានយកជាគោល។

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ០៨៣៩ Et/២០១២

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## មាតិកា


| | ទំព័រ |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប | ៣ - ៤ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប | ៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេប | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេប | ៧ - ៨ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ៩ - ១៩ |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុសង្ខេបរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា (“រ.ទ.ស.ភ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប របាយការណ៍បម្រែបម្រួលមូលធនសង្ខេប និង របាយការណ៍លំហូរសាច់ប្រាក់សង្ខេប សម្រាប់ត្រីមាស និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុបន្ថែមផ្សេងៗ(ត្រូវបានគេស្គាល់ផងដែរថាជា “ព័ត៌មានហិរញ្ញវត្ថុ សង្ខេបបណ្តោះអាសន្ន”) បានរៀបចំឡើងត្រឹមត្រូវគ្រប់ទិដ្ឋភាពជាសារវ័ន្តទាំងអស់ ទៅតាមស្តង់ដារគណនេយ្យ អន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី “*របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា*”។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាល.

**ឯកឧត្តម ស៊ឹម ស៊ីថា**
អគ្គនាយក

**លោក រស់ គឹមលាង**
អគ្គនាយករងទទួលបន្ទុក
ការងារហិរញ្ញកិច្ច និងផ្សារមូលបត្រ

**ឯកឧត្តម សឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧

Tel: +855 23 218 128
Fax:+855 23 993 225
www.bdo.com.kh

Suite 28 Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



# របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ជូនចំពោះភាគហ៊ុនិករបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខ Co. ០៨៣៩ Et/២០១២)

## សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវ របាយការណ៍ហិរញ្ញវត្ថុសង្ខេបរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញហៅកាត់ថា "រ.ទ.ស.ភ" ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធននិង របាយការណ៍លំហូរសាច់ប្រាក់សម្រាប់រយៈពេល៣ខែ និងសេចក្តីសង្ខេបកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុបន្ថែមផ្សេងៗ (ត្រូវបានគេស្គាល់ផងដែរថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន")។ ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ជាអ្នកទទួលការខុសត្រូវក្នុងការរៀបចំនិងបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន។ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នដោយផ្អែកលើការត្រួតពិនិត្យឡើងរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាម ស្តង់ដារអន្តរជាតិកម្ពុជាលើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី "ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុក្នុងគ្រា ដែលធ្វើឡើងដោយសវនករឯករាជ្យរបស់រ.ទ.ស.ភ"។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការអនុវត្តនូវការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថាបានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងកំណត់បាន ប្រសិនបើធ្វើសវនកម្ម។ ដូច្នេះយើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះទេ។

## សេចក្តីសន្និដ្ឋាន

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ យើងខ្ញុំកត់សម្គាល់ឃើញថា មិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំជឿជាក់ថាព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបរបស់ រ.ទ.ស.ភ ដែលបានភ្ជាប់មកជាមួយនេះ មិនបានរៀបចំឡើងគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ មិនស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជាលេខ ៣៤ ស្តីពី "របាយការណ៍-ហិរញ្ញវត្ថុក្នុងគ្រា" នោះទេ។

BDO CAMBODIA

ប៊ី ឌី អូ (ខេមបូឌា) លីមីធីត

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប
## គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧ គិតជាពាន់រៀល | បានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៦ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | ៤ | ១.០៥៤.០៦៦.៩២១ | ១.០៣៦.៤០៩.៥៣៩ |
| ទ្រព្យសកម្មអរូបី | | ២.៤១០.៥៧០ | ១.៩៧៤.១៨៤ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិសាត់ | | ២១៨.៤៩៦ | ២៥៤.៧៤៥ |
| | | ១.០៥៦.៦៩៥.៩៨៧ | ១.០៣៨.៦៣៨.៤៦៨ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | | ៤៧.១១៦.២១៨ | ៤៨.៣៩៤.៤០៣ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | | ៣៧.០១៤.៦៧៣ | ៣៤.៩៩៤.៥៤៥ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ១២៧.២៨៩ | ១២៣.១១២ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | | ៥.៦០៨.៧៨៧ | ៥.៦០៨.៧៨៧ |
| វិនិយោគរយៈពេលខ្លី | ៥ | ១៤៨.២៩៤.៦៧២ | ១៤៨.២៧១.៣៨៤ |
| គណនីពន្ធផ្សេងៗត្រូវទទួល | | ៥.៣១២.០៥២ | ៥.៣១២.០៥២ |
| សមតុល្យសាច់ប្រាក់ និងធនាគារ | | ៩.៦២៩.៩៣៤ | ១៦.៣៨៦.៨៤៩ |
| | | ២៥៣.១០៣.៦២៥ | ២៥៩.០៩១.១៣២ |
| **ទ្រព្យសកម្មសរុប** | | ១.៣០៩.៧៩៩.៦១២ | ១.២៩៧.៧២៩.៦០០ |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន | | ៥៤១.២២៧.២៨២ | ៥៤១.២២៧.២៨២ |
| ទុនបម្រុង | ៦ | ២៦៤.៨២៩.៦៧៨ | ២២៩.៤៧១.៤១០ |
| ចំណេញរក្សាទុក | | ១១.៣៣៥.៦៤៨ | ៤៩.២៧៣.១០៤ |
| **មូលធនរបស់ភាគហ៊ុនិកសរុប** | | ៨១៧.៣៩២.៦០៨ | ៨១៩.៩៧១.៧៩៦ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ៧ | ២៦១.០១៨.៤៧០ | ២៥១.៦១៦.២១៩ |
| កាតព្វកិច្ចសោធននិវត្តន៍ | ៨ | ៣៤.៨០៤.៤៧៣ | ៣៣.៩៨៣.៤៧៧ |
| ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ៩ | ២៧.២៦០.៩៨០ | ២៧.៨៥០.៩៧៤ |
| បំណុលពន្ធពន្យារ | | ២៩.៧៤៥.២៤៦ | ៣១.១៣០.៨៦៩ |
| គណនីត្រូវបង់ផ្សេងៗ | ១០ | ៤៦.៦៣៧.៦៩១ | ៥៤.៩២២.៣១៦ |
| | | ៣៩៩.៤៦៦.៨៦០ | ៣៩៩.៥០៣.៨៥៥ |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប (ត)
## គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧ គិតជាពាន់រៀល | បានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៦ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលខ្លី** | | | |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១០ | ៤៥.០០២.៨១៣ | ៣៣.៣៨៤.២៧០ |
| ប្រាក់កម្ចី | ៧ | ២៧.១៥៩.៨៩១ | ៣៤.៦៩៥.៧៥៨ |
| ភាគលាភត្រូវបង់ | ១១ | ១៣.៩១៤.៨៣៦ | - |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | | ៦.៨៦២.៦០៤ | ១០.១៧៣.៩២១ |
| | | ៩២.៩៤០.១៤៤ | ៧៨.២៥៣.៩៤៩ |
| **បំណុលសរុប** | | ៤៩២.៤០៧.០០៤ | ៤៧៧.៧៥៧.៨០៤ |
| **មូលធនរបស់ភាគហ៊ុនិក និងបំណុលសរុប** | | ១.៣០៩.៧៩៩.៦១២ | ១.២៩៧.៧២៩.៦០០ |

*របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបគួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលបានធ្វើ សវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្ដោះអាសន្ននេះ។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប
## សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧[១] គិតជាពាន់រៀល | ៣១ មីនា ២០១៦[២] គិតជាពាន់រៀល |
|---|---|---|---|
| ចំណូល៖ | | | |
| ការលក់ | | ៤៦.០៤៥.០៩២ | ៤៣.១៨៧.៩៣០ |
| ចំណូលពីការសាងសង់ | | ៥.៩៩៨.២៩៩ | ៣.៣៣៥.៨៤៨ |
| ចំណូលផ្សេងៗ | | ៤.១៧០.១១៧ | ២.៧១៩.៥០៦ |
| | | ៥៦.២១៣.៥០៨ | ៤៩.២៤៣.២៨៤ |
| ចំណាយ៖ | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (៩.២៨២.០៩៣) | (៨.៨៩៥.០២២) |
| ចំណាយថ្លៃភ្លើង | | (៨.៧៤៣.៥៨២) | (៨.១៤៤.០៦៦) |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ | | (៩.៩៨៣.៤០៧) | (៨.៦៣៥.៤៧២) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | | (១.៦៧៩.៥៣៧) | (១.៩០២.១០៣) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទៅតាមគេហដ្ឋាន | | (២.៧៣០.៨៥៧) | (២.៣៥៣.៩៧២) |
| ចំណាយជួសជុល និងថែទាំ | | (១.៦២៣.០៦១) | (១.៥៣៧.៣២៣) |
| ចំណាយសេវាសាងសង់ | | (៤.៧១៨.៨២០) | (២.២០១.៤៥០) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១.៥៤៤.៧៣៦) | (៨៦៩.៦០៧) |
| ខាតពីការប្តូររូបិយប័ណ្ណ - សុទ្ធ | | (១.២២៧.៧៨៣) | (១.៩៩៨.៧១៦) |
| | | (៤១.៥៣៣.៨៧៦) | (៣៦.៥៣៧.៧៣១) |
| ចំណេញប្រតិបត្តិការ | | ១៤.៦៧៩.៦៣២ | ១២.៧០៥.៥៥៣ |
| ចំណូលការប្រាក់ | ១២ | ២.២៩០.៥៩៣ | ៣.២៥៦.៦៤២ |
| ចំណាយការប្រាក់ | ១២ | (២.៧០៩.១៦៤) | (៦.៤២៧.៨១៩) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ១៤.២៦១.០៦១ | ៩.៥៣៤.៣៧៦ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៣ | (២.៩៤៥.៣៣២) | (១.៩៥៣.៤៨៧) |
| ចំណេញក្នុងការិយបរិច្ឆេទ | | ១១.៣១៥.៧២៩ | ៧.៥៨០.៨៨៩ |
| ចំណូលលម្អិតផ្សេងៗ | | | |
| ខ្ទង់គណនីដែលមិនបានបែងចែកចំណេញ ឬខាត៖ | | | |
| ចំណេញពីការវាយតម្លៃហានិភ័យភាគពួកិច្ចសោធននិវត្តន៍ | | ១៩.៩១៩ | - |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ១១.៣៣៥.៦៤៨ | ៧.៥៨០.៨៨៩ |
| ចំណេញក្នុង១ភាគហ៊ុន (ជាប្រាក់រៀល) របស់ភាគហ៊ុននិក រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖ | | | |
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (Basic earnings per share) | ១៤ | ១៣០.៣៤ | ៨៧.១៦ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (Diluted earnings per share) | ១៤ | ១៣០.៣៤ | ៨៧.១៦ |

*កំណត់សម្គាល់៖*

*(១) របាយការណ៍បម្រែបម្រួលសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទ បានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្ម។*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេប
## សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | មូលធនភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| មិនបានធ្វើសវនកម្ម | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ | | ៥៤១.២២៧.២៨២ | ២២៩.៤៧១.៤១០ | ៤៩.២៧៣.១០៤ | ៨១៩.៩៧១.៧៩៦ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | ១១.៣១៥.៧២៩ | ១១.៣១៥.៧២៩ |
| ការចំណេញ ដែលបណ្តាលមកពីការវាយតម្លៃហានិភ័យសោធននិវត្តន៍ | | - | - | ១៩.៩១៩ | ១៩.៩១៩ |
| លទ្ធផលលម្អិតសរុប ក្នុងការិយបរិច្ឆេទ | | - | - | ១១.៣៣៥.៦៤៨ | ១១.៣៣៥.៦៤៨ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ៦ | - | ៣៥.៣៥៨.២៦៨ | (៣៥.៣៥៨.២៦៨) | - |
| ភាគលាភត្រូវបង់ | ១១ | - | - | (១៣.៩១៤.៨៣៦) | (១៣.៩១៤.៨៣៦) |
| សរុបប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | - | ៣៥.៣៥៨.២៦៨ | (៤៩.២៧៣.១០៤) | (១៣.៩១៤.៨៣៦) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ (១) | | ៥៤១.២២៧.២៨២ | ២៦៤.៨២៩.៦៧៨ | ១១.៣៣៥.៦៤៨ | ៨១៧.៣៩២.៦០៨ |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | | ៥៤១.២២៧.២៨២ | ១៨៥.៧៩១.៧៧២ | ៥៦.៨៤៩.១៣១ | ៧៨៣.៨៦៨.១៨៥ |
| ចំណេញក្នុងការិយបរិច្ឆេទ រួមទាំងចំណូលផ្សេងៗ | | - | - | ៧.៥៨០.៨៨៩ | ៧.៥៨០.៨៨៩ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ៦ | - | ៤៣.៦៧៩.៦៣៨ | (៤៣.៦៧៩.៦៣៨) | - |
| ភាគលាភត្រូវបង់ | | - | - | (១៣.២៦៩.៤៩០) | (១៣.២៦៩.៤៩០) |
| សរុបប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | - | ៤៣.៦៧៩.៦៣៨ | (៥៦.៩៤៩.១២៨) | (១៣.២៦៩.៤៩០) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ (២) | | ៥៤១.២២៧.២៨២ | ២២៩.៤៧១.៤១០ | ៧.៥៨០.៨៩២ | ៧៧៨.២៧៩.៥៨៤ |

*កំណត់សម្គាល់៖*

*(១) របាយការណ៍បម្រែបម្រួលសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទ បានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្ម។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧(១) គិតជាពាន់រៀល | ៣១ មីនា ២០១៦(២) គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| ចំណេញមុនបង់ពន្ធ | | ១៤.២៦១.០៦១ | ៩.៥៣៤.៣៧៦ |
| និយ័តកម្ម៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | | ១៧៥.៨៧៣ | ១៩៣.៧៧៨ |
| រំលស់ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | (៥៨៩.៩៩៤) | (៥៨៩.៩៩៣) |
| រំលស់ទ្រព្យសកម្មរូបី | ៤ | ៩.១០៦.២១៩ | ៨.៧០១.២៤៤ |
| ចំណូលការប្រាក់ | | (២.២៩០.៥៩៣) | (៣.២៥៦.៦៤២) |
| ចំណាយការប្រាក់ | | ២.៧០៩.១៦៤ | ៩.២៤៣.៨៦៦ |
| ការជំរះបញ្ជីចេញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | - | ៣០.២៨៩ |
| ចំណាយកាតព្វកិច្ចសោធននិវត្តន៍ | ៨ | ១.១១៧.៩៥៦ | ១.០០៩.០១៥ |
| ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ២៤.៤៨៩.៦៨៦ | ២៤.៨៦៥.៩៣៣ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | ១.២៧៨.១៨៥ | (១.៦៧០.២៧០) |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | (១.៤១៨.៩៧០) | ៨៥០.៩៩៨ |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | | ៤.៥០៣.១៦៩ | ៣.០៣៦.៩៣៣ |
| ប្រាក់កក់របស់អតិថិជន | | ១.១៥២.៧១៣ | ១.០៧៩.២១៩ |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ៣០.០០៤.៧៨៣ | ២៨.១៦២.៤១៣ |
| ចំណូលពន្ធបានបង់ | | (៧.៦៤២.២៧២) | (១០.១៤៩.៩១៥) |
| កាតព្វកិច្ចសោធននិវត្តន៍បានបង់ | | (២៧៧.០៤១) | (២៧៤.៣៩០) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ២២.០៨៥.៤៧០ | ១៧.៧៣៨.១០៨ |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | (២៨.៩៩៤.១៤១) | (២១.៦៥៤.២៤៩) |
| ការទិញទ្រព្យសម្បត្តិអរូបិយ | | (៦១២.២៥៩) | - |
| មូលធនការប្រាក់លើទ្រព្យសម្បត្តិដែលមានលក្ខណៈគ្រប់គ្រាន់ | | (៩១.៤២៤) | (៩៤.៩៧២) |
| ទឹកប្រាក់សំណងពីគណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ៣២.០៧២ | ៣១.៨២៥ |
| ការវិនិយោគរយៈពេលខ្លី | | (២៣.២៨៨) | ៤.៩១២.៩៤០ |
| ការប្រាក់បានទទួល | | ៩៦៣.៧៩៤ | ៣.៨០១.៤៣៨ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (២៨.៧២៥.២៤៦) | (១៣.០០៣.០១៨) |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧[១] គិតជាពាន់រៀល | ៣១ មីនា ២០១៦[២] គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់សុទ្ធបពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ៩.៦៥២.១៨៧ | ៧.៨៦៥.៣៣០ |
| ការប្រាក់បានបង់ | | (៤.៤៤៣.១៦៨) | (៥.៩៤៤.៩៨៩) |
| ការបង់សងប្រាក់កម្ចី | | (៥.៣២៦.១៥៨) | (៥.៣៣២.០០៨) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | (១១៧.១៣៩) | (៣.៤១១.៦៦៧) |
| **(តំហយ)/កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៦.៧៥៦.៩១៥) | ១.៣២៣.៤២៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ១៦.៣៨៦.៨៤៩ | ១២.៥៥៥.៤៣៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | ៩.៦២៩.៩៣៤ | ១៣.៨៧៨.៨៥៨ |

*កំណត់សម្គាល់៖*

*(១) របាយការណ៍បម្រែបម្រួលសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទបានពិនិត្យឡើងវិញប៉ុន្តែមិនបានធ្វើសវនកម្ម។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

### ១. ព័ត៌មានអំពីក្រុមហ៊ុន

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈ សេដ្ឋកិច្ច និងមានលេខចុះបញ្ជី Co.០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេប ត្រូវបានបង្ហាញជាប្រាក់រៀលដែលជារូបិយវត្ថុដែល រ.ទ.ស.ភ កំពុងប្រើប្រាស់ផងដែរ។

ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេប ត្រូវបានអនុម័តឲ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧។

### ២. សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងការចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម សេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងអនុលោមតាមច្បាប់
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍន៍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឲ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម

### ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នមិនត្រូវបានធ្វើសវនកម្ម ហើយត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន*។ របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ គួរតែត្រូវបានអានផ្ទួបផ្សំ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងកំណត់សម្គាល់មួយចំនួនដែលអមជាមួយ។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

កំណត់សម្គាល់មួយចំនួន ត្រូវបានជ្រើសរើសដាក់ភ្ជាប់មកជាមួយដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗ សម្រាប់ការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលអាជីវកម្មរបស់ រ.ទ.ស.ភ ចាប់គិតពីត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

គោលការណ៍គណនេយ្យ និងវិធីសាស្ត្រនៃការគណនាដែលបានអនុវត្ត គឺសមស្របទៅនឹងគោលការណ៍ និងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ លើកលែងតែការអនុវត្តនៃវិសោធនកម្ម និងបំណកស្រាយផ្សេងៗខាងក្រោមៈ

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១ *ការពង្រឹងប្រចាំឆ្នាំ (ខួប២០១៤ ដល់ ២០១៦)* | ១ មករា ២០១៧ |
| វិសោធនកម្មលើ ស.គ.អ.ក ១២ *ការទទួលស្គាល់ពន្ធពន្យា នៃការខាតមិនបានទទួលស្គាល់* | ១ មករា ២០១៧ |
| វិសោធនកម្មលើ ស.គ.អ.ក ៧ *ការតាំងបង្ហាញ* | ១ មករា ២០១៧ |

ពុំមានការប៉ះពាល់ជាសារវ័ន្តទៅលើការអនុវត្តនៃវិសោធនកម្ម ក្នុងកំឡុងការិយបរិច្ឆេទនៃគ្រាហិរញ្ញវត្ថុនេះទេ។

ខាងក្រោមនេះ គឺជាស្តង់ដាគណនេយ្យ វិសោធនកម្ម និងបំណកស្រាយផ្សេងៗ ដែលត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តដោយរ.ទ.ស.ភៈ

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១ *ការពង្រឹងប្រចាំឆ្នាំ (ខួប២០១៤ ដល់ ២០១៦)* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ២ *ការបែងចែក និង ការវាស់វែងតំលៃនៃប្រតិបត្តិការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុន* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ (ចេញផ្សាយដោយ ក.ប.ស.គ.អ នៅខែកក្កដាឆ្នាំ២០១៤)* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* | ១ មករា ២០១៨ |
| ការបញ្ជាក់ពី ស.រ.ហ.អ.ក ១៥ | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការពង្រឹងប្រចាំឆ្នាំ (ខួប២០១៤ ដល់ ២០១៦)* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ៤០ *ការផ្ទេរទ្រព្យសម្បត្តិវិនិយោគ* | ១ មករា ២០១៨ |
| ការបកស្រាយ ២២ *ប្រតិបត្តិការរូបិយប័ណ្ណបរទេស និងបុរេប្រទាននៃតម្លៃតបស្នង* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ១៦ *ការជួល* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យ រវាងសហគ្រិន និងញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ពន្យា |

រ.ទ.ស.ភ កំពុងវិភាគលើផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និងការបកស្រាយ ដោយហេតុផលប៉ះពាល់ទាំងនេះអាចប៉ាន់ស្មានបានសម្រាប់តែការិយបរិច្ឆេទនាពេលអនាគតប៉ុណ្ណោះ។

## ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | មិនបានធ្វើសវនកម្ម ៣១ មីនា ២០១៧[១] គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៦[២] គិតជាពាន់រៀល |
|---|---|---|
| ***ថ្លៃដើម*** | | |
| សមតុល្យដើមគ្រា/ឆ្នាំ | ១.៣៧១.០០៤.៤៥៨ | ១.២៣៩.៧៥៥.៩៥២ |
| ការទិញបន្ថែម | ២៦.៧៦៣.៦០១ | ១៣៥.៤៨៤.៤១៥ |
| ការលក់ | - | (៤.២៣៥.៩០៩) |
| សមតុល្យចុងគ្រា/ឆ្នាំ | ១.៣៩៧.៧៦៨.០៥៩ | ១.៣៧១.០០៤.៤៥៨ |
| ***រំលស់បង្គរ*** | | |
| សមតុល្យដើមគ្រា/ឆ្នាំ | ៣៣៤.៥៩៤.៩១៩ | ៣០៣.០៤៤.០១៥ |
| រំលស់ក្នុងឆ្នាំ | ៩.១០៦.២១៩ | ៣៥.២៦៦.០១០ |
| ការលក់ | - | (៣.៧១៥.១០៦) |
| សមតុល្យចុងគ្រា/ឆ្នាំ | ៣៤៣.៧០១.១៣៨ | ៣៣៤.៥៩៤.៩១៩ |
| ***តម្លៃពិតគណនេយ្យ*** | | |
| សមតុល្យចុងគ្រា/ឆ្នាំ | ១.០៥៤.០៦៦.៩២១ | ១.០៣៦.៤០៩.៥៣៩ |

ក្នុងអំឡុងពេលហិរញ្ញវត្ថុរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានធ្វើការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទូទាត់ជាសាច់ប្រាក់ដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧ គិតជាពាន់រៀល | ៣១ មីនា ២០១៦ គិតជាពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ២៦.៧៦៣.៦០១ | ២២.០០១.៦១៧ |
| កំណើន/(តំហយ)គណនីផ្គត់ផ្គង់ និងប្រាក់ធានាប្រតិបត្តិការ | ២.៣២១.៩៦៤ | (២៥២.៣៩៦) |
| ការធ្វើមូលធនកម្មការប្រាក់ចំណាយលើទ្រព្យសកម្ម | (៩១.៤២៤) | (៩៤.៩៧២) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ទូទាត់ជាសាច់ប្រាក់ | ២៨.៩៩៤.១៤១ | ២១.៦៥៤.២៤៩ |

## ៥. ការវិនិយោគរយៈពេលខ្លី

ការវិនិយោគរយៈពេលខ្លីគឺជាប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់រយៈពេល៤ខែ ទៅ ១២ខែ ហើយទទួលបានការប្រាក់ចាប់ពី៤% និង៥%ក្នុងមួយឆ្នាំ។

ការវិនិយោគរយៈពេលខ្លីរួមមានប្រាក់បញ្ញើក្នុងទឹកប្រាក់ចំនួន ១៤.៨ ពាន់លានរៀល (២០១៦: ១៤.៨ ពាន់លានរៀល) ដែលតម្កល់ទុកជាពិសេសសម្រាប់ការបង់កាតព្វកិច្ចសោធននិវត្តន៍ជូនបុគ្គលិកដែលត្រូវចូលនិវត្តន៍ ដែលមានសិទ្ធិទទួលអត្ថប្រយោជន៍ពេលចូលនិវត្តន៍នៅក្នុងគម្រោងនេះ។

## ៦. ទុនបម្រុង

| | ដើមទុនបម្រុង គិតជាពាន់រៀល | ទុនបម្រុងស្របច្បាប់ គិតជាពាន់រៀល | ទុនបម្រុងទូទៅ គិតជាពាន់រៀល | ទុនបម្រុងសម្រាប់ធ្វើការវិនិយោគ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី១ មករា ២០១៧** | ១.៦៤៨.៤៣៥ | ១៨.២៣៨.៣៨៨ | ១៨.២៣៨.៣៨៨ | ១៩១.៣៤៦.១៩៩ | ២២៩.៤៧១.៤១០ |
| ផ្ទេរពីចំណេញរក្សាទុក | - | ២.៤៦៣.៦៥៣ | ២.៤៦៣.៦៥៣ | ៣០.៤៣០.៩៦២ | ៣៥.៣៥៨.២៦៨ |
| **គិតត្រឹមថ្ងៃទី៣១ មីនា ២០១៧ (មិនបានធ្វើសវនកម្ម)** | ១.៦៤៨.៤៣៥ | ២០.៧០២.០៤១ | ២០.៧០២.០៤១ | ២២១.៧៧៧.១៦១ | ២៦៤.៨២៩.៦៧៨ |
| **គិតត្រឹមថ្ងៃទី១ មករា ២០១៦** | ១.៦៤៨.៤៣៥ | ១៥.៣៩០.៩៣៣ | ១៥.៣៩០.៩៣៣ | ១៥៣.៣៦១.៤៧១ | ១៨៥.៧៩១.៧៧២ |
| ផ្ទេរពីចំណេញរក្សាទុក | - | ២.៨៤៧.៤៥៥ | ២.៨៤៧.៤៥៥ | ៣៧.៩៨៤.៧២៨ | ៤៣.៦៧៩.៦៣៨ |
| **គិតត្រឹមថ្ងៃទី៣១ ធ្នូ២០១៦ (បានធ្វើសវនកម្ម)** | ១.៦៤៨.៤៣៥ | ១៨.២៣៨.៣៨៨ | ១៨.២៣៨.៣៨៨ | ១៩១.៣៤៦.១៩៩ | ២២៩.៤៧១.៤១០ |

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាលបានអនុម័តផ្ទេរប្រាក់ចំណេញរក្សាទុកទៅគណនីទុនបម្រុង ដែលមានទឹកប្រាក់ចំនួន ៣៥.៣៥៨លានរៀល។

យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១២ ត្រង់មាត្រា ៤៤ បានចែងថាប្រាក់ចំណេញរបស់ រ.ទ.ស.ភ បន្ទាប់ពីការកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ប្រាក់រង្វាន់របស់គណៈគ្រប់គ្រង និងបុគ្គលិក
- សម្រាប់ទុនបម្រុងស្របច្បាប់ ៥%
- សម្រាប់ទុនបម្រុងទូទៅ ៥%
- សមតុល្យនៅសល់សម្រាប់ទុនបម្រុងការអភិវឌ្ឍ។

## ៧. ប្រាក់កម្ចី

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១០៧៥ ០៣ S | ៣០.០៦៤.៣៧៧ | ២៩.៩៧៣.៤៧៣ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | ៧៩.៦៨៥.៩០៤ | ៨០.៣២២.៥៥៦ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ៦០០០ ០១ G | ៥.៤៤៥.៣២៤ | ៥.៤២៨.៨៦០ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – ធនាគារអភិវឌ្ឍន៍អាស៊ី | ៣១.៣៣៤.១៣៤ | ៣១.៣៣៤.១៣៤ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | ១១៤.៤៨៨.៧៣១ | ១០៤.៥៥៧.១៥៦ |
| | ២៦១.០១៨.៤៧០ | ២៥១.៦១៦.២១៩ |
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១០៧៥ ០៣ S | ៨.៧០៤.១៥២ | ៨.៥៩៣.០៥៣ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | ៤.៨៧៨.១១៣ | ១១.៣៣១.២៤៦ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ៦០០០ ០១ G | ៥.៤៨៥.៨៩១ | ៥.៤២៨.៨៦០ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – ធនាគារអភិវឌ្ឍន៍អាស៊ី | ១.០៨៥.៩៥១ | ២.២៧៧.៩៨១ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | ៧.០០៥.៧៨៤ | ៧.០៦៤.៦១៨ |
| | ២៧.១៥៩.៨៩១ | ៣៤.៦៩៥.៧៥៨ |
| | ២៨៨.១៧៨.៣៦១ | ២៨៦.៣១១.៩៧៧ |

កាលបរិច្ឆេទផុតកំណត់របស់ប្រាក់កម្ចីនេះមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| -ផុតកំណត់ក្នុងរយៈពេល ១ឆ្នាំ | ២៧.១៥៩.៨៩១ | ៣៤.៦៩៥.៧៥៨ |
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| -ផុតកំណត់ក្នុងរយៈពេល ១ឆ្នាំ ទៅ ២ឆ្នាំ | ៥៣.៤៣៤.២១៧ | ៣៨.៦៨៨.៩៧០ |
| -ផុតកំណត់ក្នុងរយៈពេល ២ឆ្នាំ ទៅ ៥ឆ្នាំ | ៩៩.០៧០.៨៨៩ | ៩៥.៤៩៨.៤០៥ |
| -ផុតកំណត់ក្នុងរយៈពេល ៥ឆ្នាំ | ១០៨.៥១៣.៣៦៤ | ១១៧.៤២៨.៨៤៤ |
| | ២៦១.០១៨.៤៧០ | ២៥១.៦១៦.២១៩ |
| | ២៨៨.១៧៨.៣៦១ | ២៨៦.៣១១.៩៧៧ |

## ៨. កាតព្វកិច្ចសោធននិវត្តន៍

ចំនួនដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៣៤.៨០៤.៤៧៣ | ៣៣.៩៨៣.៤៧៧ |
| តម្លៃសមស្របនៃទ្រព្យតម្កល់ | - | - |
| បំណុលដែលបានកត់ត្រានៅក្នុងគោលការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៣៤.៨០៤.៤៧៣ | ៣៣.៩៨៣.៤៧៧ |

បម្រែបម្រួលនៅក្នុងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងកំឡុងឆ្នាំនេះ មានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| **សមតុល្យនៅថ្ងៃទី១ ខែមករា** | ៣៣.៩៨៣.៤៧៧ | ២៩.៨៥២.៣៩១ |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៤៥០.១៦៥ | ៤០០.៩៩១ |
| ចំណាយការប្រាក់ | ៦៦៧.៧៩១ | ៦០៨.០២៣ |
| អត្ថប្រយោជន៍បានបង់ | (២៧៧.០៤១) | (២៧៤.៣៩០) |
| ការចំណេញដែលបណ្ដាលមកពីការវាយតម្លៃហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | (១៩.៩១៩) | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែមីនា** | ៣៤.៨០៤.៤៧៣ | ៣០.៥៨៧.០១៥ |

ទឹកប្រាក់ដែលបានកត់ត្រាក្រោមខ្ទង់ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| ចំណាយលើសេវាបច្ចុប្បន្ន | ៤៥០.១៦៥ | ៤០០.៩៩២ |
| ចំណាយការប្រាក់ | ៦៦៧.៧៩១ | ៦០៨.០២៣ |
| | ១.១១៧.៩៥៦ | ១.០០៩.០១៥ |

## ៩. ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ

| | ជំនួយពី រដ្ឋាភិបាល គិតជាពាន់រៀល | ជំនួយពី JICA គិតជាពាន់រៀល | ជំនួយផ្សេងៗ គិតជាពាន់រៀល | សរុបរួម គិតជាពាន់រៀល |
|---|---|---|---|---|
| **សមតុល្យនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៧** | ៤.៨៦៥.០៥៩ | ២២.២០៤.៤២២ | ៧៨១.៤៩៣ | ២៧.៨៥០.៩៧៤ |
| ការដករំលស់ទៅទ្រព្យសកម្មអរូបិយ | (៥៦.៧២៥) | (៥២៧.១៧០) | (៦.០៩៩) | (៥៨៩.៩៩៤) |
| **សមតុល្យនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | ៤.៨០៨.៣៣៤ | ២១.៦៧៧.២៥២ | ៧៧៥.៣៩៤ | ២៧.២៦០.៩៨០ |
| **សមតុល្យនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៦** | ៥.០៩១.៩៥៦ | ២៤.៣១៣.១០២ | ៨០៥.៨៨៨ | ៣០.២១០.៩៤៦ |
| ការដករំលស់ទៅទ្រព្យសកម្មអរូបិយ | (២២៦.៨៩៧) | (២.១០៨.៦៨០) | (២៤.៣៩៥) | (២.៣៥៩.៩៧២) |
| **សមតុល្យនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦** | ៤.៨៦៥.០៥៩ | ២២.២០៤.៤២២ | ៧៨១.៤៩៣ | ២៧.៨៥០.៩៧៤ |

## ១០. គណនីពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម ៣១ មីនា ២០១៧ គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៦ គិតជាពាន់រៀល |
|---|---|---|
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ - រយៈពេលវែង** | | |
| ប្រាក់កក់របស់អតិថិជន | ៤៦.៦៣៧.៦៩១ | ៤៥.៤៨៤.៩៧៨ |
| ប្រាក់ធានាប្រតិបត្តិការ | - | ៩.៤៣៧.៣៣៨ |
| | ៤៦.៦៣៧.៦៩១ | ៥៤.៩២២.៣១៦ |
| **គណនីអ្នកផ្គត់ផ្គងពាណិជ្ជកម្ម - រយៈពេលខ្លី** | | |
| ភាគីទី៣ | ២០.០៤១.៤៧៩ | ១២.៧៤២.៧៤០ |
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ - រយៈពេលខ្លី** | | |
| បង្គរប្រាក់លើកទឹកចិត្តបុគ្គលិក | ៦.៦៨៨.៥៥៤ | ៥.៥៨៣.២០៨ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ១២.៧១៥.៩៧១ | ១១.១៤៤.១១៦ |
| ប្រាក់ធានាប្រតិបត្តិការ | ១០២.៨៩៥ | ១០៧.៣៥១ |
| ចំណូលមិនទាន់សម្រេច | ៩៨២.៥៤៩ | ១.៣៨៦.៣៤៦ |
| ចំណូលពន្យារ | ៥.២៨១ | ៥.២៧៨ |
| ពន្ធត្រូវបង់ផ្សេងៗ | ២២៣.៦៤៨ | ១៨២.៨៤៦ |
| គណនីត្រូវបង់ផ្សេងៗ | ៤.២៤២.៤៣៦ | ២.២៣២.៣៨៥ |
| | ២៤.៩៦១.៣៣៤ | ២០.៦៤១.៥៣០ |
| | ៤៥.០០២.៨១៣ | ៣៣.៣៨៤.២៧០ |
| | ៩១.៦៤០.៥០៤ | ៨៨.៣០៦.៥៨៦ |

## ១១. ភាគលាភត្រូវបង់

នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាលបានស្នើ និងអនុម័តភាគលាភសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានតម្លៃ១៥៩.៩៩រៀល ក្នុងមួយហ៊ុន និងមានភាគលាភសរុបចំនួន ១៣.៩១៤លានរៀលជូនភាគហ៊ុននិក។

## ១២. ចំណូល/ (ចំណាយ)ការប្រាក់

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០១៧ គិតជាពាន់រៀល | ៣១ មីនា ២០១៦ គិតជាពាន់រៀល |
|---|---|---|
| ចំណូលហិរញ្ញវត្ថុ: | | |
| - ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ១.៥២៦.២៤១ | ៣.២៥០.៧៩៤ |
| - ចំណូលហិរញ្ញប្បទានអនុគ្រោះឲ្យបុគ្គលិកកត់ត្រាត្រលប់វិញ | - | - |
| - ចំណូលពីការប្តូររូបិយប័ណ្ណលើកម្ចី | ៧៥៩.៨៩៧ | - |
| - ចំណូលការប្រាក់ពីឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៤.៤៥៥ | ៥.៨៤៨ |
| | ២.២៩០.៥៩៣ | ៣.២៥៦.៦៤២ |
| ចំណាយការប្រាក់: | | |
| - ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (២.៣៥០.២៥៥) | (៩.៣៣៨.៨៤៥) |
| - ខាតសុទ្ធពីការប្តូររូបិយប័ណ្ណរបស់ប្រាក់កម្ចី | (៤៥០.៣៣៣) | ២.៨១៦.០៥៤ |
| - ចំណាយការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមានគុណវុឌ្ឍិ | ៩១.៤២៤ | ៩៤.៩៧២ |
| | (២.៧០៩.១៦៤) | (៦.៤២៧.៨១៩) |
| | (៤១៨.៥៧១) | (៣.១៧១.១៧៧) |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើផ្សេងៗ ដែលធ្វើនៅក្នុងធនាគារក្នុងស្រុកក្នុងឆ្នាំ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចីពីAfD និងប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង JICA។

## ១៣. ចំណាយពន្ធលើប្រាក់ចំណេញ

នៅក្រោមច្បាប់សារពើពន្ធ រ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ២០% (២០១៦: ២០%) នៃចំណេញត្រូវបង់ពន្ធ ឬពន្ធអប្បបរមា១% (២០១៦: ១%)នៃផលរបរសរុបហើយជ្រើសរើសយកមួយណាដែលខ្ពស់ជាងគេ។ វាតំណាងអោយទឹកប្រាក់អប្បបរមា ដែលត្រូវបង់ជូនទៅអាជ្ញាធរពន្ធដា។ ក្រុមហ៊ុនមានបំណុលពន្ធលើប្រាក់ចំណេញ លើសបំណុលពន្ធអប្បបរមា ដូច្នេះក្រុមហ៊ុនមិនមានកាតព្វកិច្ចបង់ពន្ធអប្បរមាឡើយ។ ពន្ធដែលត្រូវបង់លុះត្រាតែក្រុមហ៊ុនស្ថិតនៅក្នុងស្ថានភាពខាតបង់ពន្ធ។ ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធនេះទោះបីជាក្រុមហ៊ុនស្ថិតក្នុងស្ថានភាពខាតក៏ដោយ។

## ១៤. ចំណេញក្នុងមួយភាគហ៊ុន

### (ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (Basic earnings per share)

ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់រ.ទ.ស.ភ ចែកនឹងចំនួនភាគហ៊ុនមធ្យម (Weighted average) ដែលបានបោះផ្សាយក្នុងការិយបរិច្ឆេទ។

| | មិនបានធ្វើសវនកម្ម<br>សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០១៧ | <br><br>៣១ មីនា ២០១៦ |
|---|---|---|
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក (គិតជាពាន់រៀល) | ១១.៣៣៥.៦៤៨ | ៧.៥៨០.៨៨៩ |
| ចំនួនភាគហ៊ុនមធ្យម | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (គិតជាពាន់រៀល) | ១៣០.៣៤ | ៨៧.១៦ |

### (ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (Diluted earnings per share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មត់ថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

គិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ រ.ទ.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះគឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

## ១៥. ប្រតិបត្តិការភាគីពាក់ព័ន្ធ

### (ក) រ.ទ.ស.ភ មានប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | <br>៣១ មីនា ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ការប្រាក់លើប្រាក់កម្ចី | ២.១៣៣.១៣៥ | ២.៣៤៣.២២៤ |
| រដ្ឋាករទឹកខេត្តពោធិ៍សាត់ | | |
| ការប្រាក់លើឥណទាន | ៤.៤៥៤ | ៥.៨៤៨ |

### (ខ) អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ

អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់កំឡុងបរិច្ឆេទ មានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០១៧<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សរ៍ និងការចំណាយផ្សេងៗ | ៥៣៦.៧០០ | ៥១៩.៦៩១ |
| អត្ថប្រយោជន៍សោធននិវត្តន៍ | ៤៤.១៩៥ | ១៥.៧២៨ |
| | ៥៨០.៨៩៥ | ៥៣៥.៤១៩ |

## ១៦. កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គឺដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អ ដែលអាចកើតឡើងដោយសារការប្រែប្រួល នៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ។ ហេតុនេះគណៈគ្រប់គ្រងបង្កើត គោលការណ៍លម្អិតដូចជាកម្រិតសិទ្ធិអំណាច ត្រួតពិនិត្យការទទួលខុសត្រូវការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ដោយ អនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

### ក. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍របស់ រ.ទ.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថា រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែល រ.ទ.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីពាណិជ្ជត្រូវទទួលពីអតិថិជនតែម្នាក់។ អាយុកាលឥណទានរបស់ រ.ទ.ស.ភ មានរយៈពេល ១ខែ ហើយ រ.ទ.ស.ភ ព្យាយាមធ្វើការគ្រប់គ្រងយ៉ាងជិតដល់ លើគណនីត្រូវទទួលដែលមិនទាន់ប្រមូលដើម្បីកាត់បន្ថយហានិភ័យឥណទានអោយទាបបំផុត។ សមតុល្យដែលហួសកំណត់ត្រូវបានពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង។

### ខ. ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួលនិងលំហូរសាច់ប្រាក់កើតឡើងពីការគ្រប់គ្រងរបស់រ.ទ.ស.ភទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល រ.ទ.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

រ.ទ.ស.ភ គ្រប់គ្រងរយៈកាលកំណត់របស់បំណុលចាស់ៗ លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្មដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការវិនិយោគ និង ហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល រ.ទ.ស.ភ ធ្វើការរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូល គ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ។

### គ. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជា ហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ រ.ទ.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងនឹងកម្ចី។ រ.ទ.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកលើបំណុលទីផ្សារហើយសំខាន់ជាងនេះទៀតគឺរក្សាអោយបានការលាយឡំគ្នារបស់អត្រាថេរ និងអត្រាអថេររបស់កម្ចី ដោយប្រុងប្រយ័ត្ន។ រ.ទ.ស.ភ ពុំបានប្រើប្រាស់ ដេរីវេទីវ ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

## ១៧. កិច្ចសន្យាទាក់ទិននឹងការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

នៅចុងត្រីមាសនៃការិយបរិច្ឆេទហិរញ្ញវត្ថុនេះ រ.ទ.ស.ភបានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនទៅលើទ្រព្យសកម្មខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣១ មិនា ២០១៧<br>គិតជាពាន់រៀល | ធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៦<br>គិតជាពាន់រៀល |
|---|---|---|
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ២.១៦៧.៧៧៣ | ១៤.០២២.៤៦៦ |
| សេវាផ្តល់ការប្រឹក្សាយោបល់ | ៨០៧.៦៣៥ | ៦.៨១៤ |
| ការទិញបំពង់ដែកស្ទិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ១.០៧៥.០៥៨ | ៣៦៦.០៤៩ |
| | ៤.០៥០.៤៦៦ | ១៤.៣៩៥.៣២៩ |